## I. លក្ខខណ្ឌនៃការប្រើប្រាស់

អ្នកប្រើប្រាស់ត្រូវមានចំណេះដឹងកុំព្យូទ័រមូលដ្ឋាន និងកម្មវិធីការិយាល័យអ៊ិចសែល(Microsoft Office Excel) តិចតួច។

ម៉ាស៊ីនកុំព្យូទ័រគួរប្រើប្រាស់កម្មវិធីការិយាល័យ (Microsoft Office) ចាប់ពីជំនាន់ឆ្នាំ២០១៦(Microsoft Office 2016) ឡើងទៅ។

ប្រព័ន្ធគ្រោងបន្ទុកបុគ្គលិក ត្រូវបានបង្កើតឡើងដោយប្រើប្រាស់កម្មវិធីការិយាល័យអ៊ិចសែល(Microsoft Office Excel) ព្រមទាំងត្រូវបានចងក្រងឡើងដោយមានការសរសេរកូដ (code) Visual Basic(VBA) សម្រាប់ដំណើរការតាមតម្រូវការជាក់ស្តែង។ ហេតុដូចនេះ បើសិនជាកម្មវិធីការិយាល័យអ៊ិចសែលរបស់លោកអ្នកមិនបានកំណត់ឲ្យ Macro ដំណើរការទេ នោះលោកអ្នកនឹងមិនអាចដំណើរការប្រព័ន្ធជាប្រក្រតីបានទេ។ ដូច្នេះ លោកអ្នកត្រូវកំណត់ឲ្យកម្មវិធីការិយាល័យអ៊ិចសែលដំណើរការ Macro ជាមុនសិន ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

1. ចុចលើ File ដែលជាម៉ឺនុយ (Menu) របស់កម្មវិធីអ៊ិចសែល(Ms Excel)




*រូបភាពទី ១*

2. ចុចលើពាក្យ Options
3. ផ្ទាំងមួយនឹងបង្ហាញឡើង សូមចុចលើពាក្យ "Trust Center"
4. ចុចលើប៊ូតុង (Button) "Trust Center Settings…"
5. ផ្ទាំងមួយទៀតបង្ហាញឡើង សូមចុចលើពាក្យ "Macro Settings"
6. សូមជ្រើសរើសយក "Enable all macros (not recommended; potentially dangerous code can run)"
7. ចុចលើប៊ូតុង OK
8. ផ្ទាំងខាងលើនឹងត្រូវបានបិទ លោកអ្នកនឹងឃើញផ្ទាំងមួយទៀត សូមចុចលើប៊ូតុង OK ម្តងទៀត
9. សូមបិទកម្មវិធីអ៊ិចសែលរួចបើកឡើងវិញ ពេលនោះប្រព័ន្ធគ្រោងបន្ទុកបុគ្គលិកនឹងដំណើរការប្រព័ន្ធបានត្រឹមត្រូវ




រូបភាពទី ២




រូបភាពទី ៣




រូបភាពទី ៤




រូបភាពទី ៥

***បញ្ជាក់៖*** *ការបង្ហាញជូនខាងលើនេះ សម្រាប់កម្មវិធីការិយាល័យអុិចសែលឆ្នាំ២០១៦(Microsoft Office Excel 2016) ចំពោះជំនាន់ផ្សេងពីនេះអាចមានទម្រង់(Interface)ផ្សេងពីនេះតិចតួច។*

## II. អំពីប្រព័ន្ធ

ប្រព័ន្ធគ្រោងបន្ទុកបុគ្គលិក គឺជាកម្មវិធីការិយាល័យអ៊ិចសែល (Microsoft Office Excel) ដែលត្រូវបានសរសេរកូដបន្ថែមលើ Microsoft Office Excel ដែលមានស្រាប់ ដើម្បីបន្ថែមមុខងារឲ្យសមស្របតាមតម្រូវការប្រើប្រាស់ជាក់ស្តែង។

## III. មូលដ្ឋាននៃការគណនា

### ក. ការប៉ាន់ស្មានគម្រោងចំណាយ

#### i. មន្ត្រីសកម្មឆ្នាំN+1

❖ មន្ត្រីសកម្មឆ្នាំN+1 ត្រូវបានគណនាតាមរូបមន្ត៖

#មន្ត្រីសកម្មឆ្នាំN+1 = (#មន្ត្រីសកម្មពីETA + #មន្ត្រីផ្ទេរចូលនិងថ្មី) - (#មន្ត្រីផ្ទេរចេញ + #មន្ត្រីឈប់ + #មន្ត្រីមរណភាព + #មន្ត្រីព្យួរ)

អត្ថន័យ៖

- #មន្ត្រីសកម្មឆ្នាំN+1 គឺជាចំនួនមន្ត្រីសកម្មដែលត្រូវប៉ាន់ស្មានថានឹងកំពុងបម្រើការនៅក្នុងឆ្នាំN+1។
- #មន្ត្រីសកម្មពីETA គឺជាចំនួនមន្ត្រីសកម្មដែលកំពុងបម្រើការឆ្នាំN ដកចេញមន្ត្រីដែលត្រូវបានចូលនិវត្តន៍ផ្តាច់ពីតារាងបៀវត្ស ដែលចំនួននេះ ត្រូវបានគណនាចេញពីតារាងបៀវត្ស(ETA)ឆ្នាំN។ ឧទាហរណ៍: #មន្ត្រីសកម្មពីETAខែមករាឆ្នាំN+1=#មន្ត្រីសកម្មឆ្នាំN - #មន្ត្រីចូលនិវត្តន៍ផ្តាច់ពីតារាងបៀវត្សត្រឹមខែមករាឆ្នាំN+1។
- #មន្ត្រីផ្ទេរចូលនិងថ្មី គឺជាចំនួនមន្ត្រីផ្ទេរចូលពីស្ថាប័នរដ្ឋផ្សេងៗ និងគ្រូចេញបម្រើការថ្មី។
- #មន្ត្រីផ្ទេរចេញ គឺជាចំនួនមន្ត្រីផ្ទេរចេញទៅស្ថាប័នរដ្ឋផ្សេងៗទៀត។
- #មន្ត្រីឈប់ គឺជាចំនួនមន្ត្រីឈប់ពីក្របខ័ណ្ឌ។
- #មន្ត្រីមរណភាព គឺជាចំនួនមន្ត្រីទទួលមរណភាព។
- #មន្ត្រីព្យួរ គឺជាចំនួនមន្ត្រីព្យួរពីការងារមួយរយៈពេលខ្លីណាមួយ។

**សម្គាល់៖** ការគណនាមន្ត្រីសកម្មឆ្នាំN+1 ត្រូវធ្វើឡើងតាមខែនីមួយៗ មានន័យថា នៅខែមករា ឆ្នាំN+1 ត្រូវគណនារកចំនួនមន្ត្រីសកម្មឆ្នាំN+1 សម្រាប់ខែមករា និងនៅខែបន្តបន្ទាប់ត្រូវគណនារកគ្រប់ខែ។

#### ii. គម្រោងចំណាយបៀវត្សមូលដ្ឋាន

មុននឹងឈានដល់ការគណនាគម្រោងចំណាយបៀវត្សមូលដ្ឋាន អ្នកត្រូវគណនា៖

❖ **បៀវត្សមូលដ្ឋាន ត្រូវបានគណនាតាមរូបមន្ត៖**

#បៀវត្សមូលដ្ឋាន = #សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ * មេគុណសន្ទស្សន៍

អត្ថន័យ៖

- #បៀវត្សមូលដ្ឋាន គឺជាបៀវត្សមូលដ្ឋានដែលមន្ត្រីរាជការម្នាក់ៗត្រូវទទួលបានតាមឋានន្តរស័ក្តិនិងថ្នាក់របស់ខ្លួន។
- #សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ គឺជាតម្លៃលេខតំណាងឱ្យឋានន្តរស័ក្តិនិងថ្នាក់។
- មេគុណសន្ទស្សន៍ គឺជាតម្លៃលេខមេគុណសន្ទស្សន៍សម្រាប់កំណត់បៀវត្សមូលដ្ឋាន។

❖ **មករា ដល់ មីនា ឆ្នាំN+1**

ពីខែមករា ដល់ មីនា ឆ្នាំN+1 បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការម្នាក់ៗត្រូវបានគណនាទៅតាមឋានន្តរស័ក្តិ និងថ្នាក់ចុងក្រោយឆ្នាំN៖

#បៀវត្សមូលដ្ឋាន = #សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN * ២៥០០

អត្ថន័យ៖

- #សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN គឺជាលេខសន្ទស្សន៍ទៅតាមឋានន្តរស័ក្តិនិងថ្នាក់ចុងក្រោយឆ្នាំN។

❖ **មេសា និង ធ្នូ ឆ្នាំN+1**

ពីខែមេសា ដល់ ធ្នូ ឆ្នាំN+1 បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការម្នាក់ៗត្រូវគិតទៅតាមឋានន្តរស័ក្តិ និងថ្នាក់ថ្មីឆ្នាំN+1 ដោយរៀងរាល់ពីរឆ្នាំម្តង មន្ត្រីរាជការដែលត្រូវបានតែងតាំងស៊ុបនឹងត្រូវបានតម្លើងមួយកាំនៅខែមេសា ដូច្នេះបៀវត្សមូលដ្ឋានត្រូវបានគណនាតាមរូបមន្ត៖

#បៀវត្សមូលដ្ឋាន = សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 * ២៥០០

**អត្ថន័យ៖**

- #សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 គឺជាតម្លៃលេខសន្ទស្សន៍ទៅតាមឋានន្តរស័ក្តិនិងថ្នាក់ចុងក្រោយខែមេសា ឆ្នាំN+1។

❖ **មន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1**

មន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 ត្រូវគណនាតាមរូបមន្ត៖

#មន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 = (#មន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN + #មន្ត្រីផ្ទេរចូលនិងថ្មីតាមឋានន្តរស័ក្តិនិងថ្នាក់) - (#មន្ត្រីផ្ទេរចេញតាមឋានន្តរស័ក្តិនិងថ្នាក់ + #មន្ត្រីឈប់តាមឋានន្តរស័ក្តិនិងថ្នាក់ + #មន្ត្រីមរណភាពតាមឋានន្តរស័ក្តិនិងថ្នាក់ + #មន្ត្រីព្យួរតាមឋានន្តរស័ក្តិនិងថ្នាក់)

អត្ថន័យ៖

- #មន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 គឺជាចំនួនមន្ត្រីសកម្មដែលប៉ាន់ស្មានថានឹងកំពុងមប្រើការនៅឆ្នាំN+1តាមឋានន្តរស័ក្តិនិងថ្នាក់។

- #មន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN គឺជាចំនួនមន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ ដែលកំពុងបម្រើការឆ្នាំN ដកចេញចំនួនមន្ត្រីចូលនិវត្តន៍តាមឋានន្តរស័ក្តិនិងថ្នាក់។
- #មន្ត្រីផ្ទេរចូលនិងថ្មីតាមឋានន្តរស័ក្តិនិងថ្នាក់ គឺជាចំនួនមន្ត្រីផ្ទេរចូលពីស្ថាប័នរដ្ឋផ្សេងៗ និងគ្រូចេញបម្រើការថ្មីតាមឋានន្តរស័ក្តិនិងថ្នាក់។
- #មន្ត្រីផ្ទេរចេញតាមឋានន្តរស័ក្តិនិងថ្នាក់ គឺជាចំនួនមន្ត្រីផ្ទេរចេញតាមឋានន្តរស័ក្តិនិងថ្នាក់ទៅស្ថាប័នរដ្ឋផ្សេងទៀត។
- #មន្ត្រីឈប់តាមឋានន្តរស័ក្តិនិងថ្នាក់ គឺជាចំនួនមន្ត្រីឈប់ពីក្របខ័ណ្ឌតាមឋានន្តរស័ក្តិនិងថ្នាក់។
- #មន្ត្រីមរណភាពតាមឋានន្តរស័ក្តិនិងថ្នាក់ គឺជាចំនួនមន្ត្រីទទួលមរណភាពតាមឋានន្តរស័ក្តិនិងថ្នាក់។
- #មន្ត្រីព្យួរតាមឋានន្តរស័ក្តិនិងថ្នាក់ គឺជាចំនួនមន្ត្រីព្យួរពីការងារមួយរយៈពេលខ្លីណាមួយតាមឋានន្តរស័ក្តិនិងថ្នាក់។

❖ **គម្រោងចំណាយបៀវត្សមូលដ្ឋានតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1**

គម្រោងចំណាយបៀវត្សមូលដ្ឋានតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 ត្រូវបានគណនាតាមរូបមន្តៈ

#គម្រោងចំណាយបៀវត្សមូលដ្ឋានតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 = #មន្ត្រីសកម្មតាមឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 * #បៀវត្សមូលដ្ឋាន

ការគណនាគម្រោងចំណាយបៀវត្សមូលដ្ឋានប្រចាំឆ្នាំ ត្រូវគណនាគម្រោងចំណាយបៀវត្សមូលដ្ឋានតាមឋានន្តរស័ក្តិនិងថ្នាក់និងតាមខែនីមួយៗជាមុនសិន បន្ទាប់មកត្រូវយកគម្រោងចំណាយបៀវត្សមូលដ្ឋានប្រចាំខែ បូកបញ្ចូលគ្នាសរុបទាំង១២ខែ។

### iii. គម្រោងចំណាយប្រាក់បំណាច់មុខងារ

មុននឹងឈានដល់ការគណនាគម្រោងចំណាយប្រាក់បំណាច់មុខងារ អ្នកត្រូវគណនាៈ

❖ មន្ត្រីសកម្មតាមមុខងារ ត្រូវបានគណនាតាមរូបមន្តៈ

#មន្ត្រីសកម្មតាមមុខងារឆ្នាំN+1 = (#មន្ត្រីសកម្មមុខងារឆ្នាំN + #មន្ត្រីផ្ទេរចូលនិងថ្មីមុខងារ) - (#មន្ត្រីផ្ទេរចេញតាមមុខងារ + #មន្ត្រីឈប់តាមមុខងារ + #មន្ត្រីមរណភាពតាមមុខងារ + #មន្ត្រីព្យួរតាមមុខងារ)

អត្ថន័យៈ

- #មន្ត្រីសកម្មតាមមុខងារឆ្នាំN+1 គឺជាចំនួនមន្ត្រីសកម្មតាមមុខងារ ដែលប៉ាន់ស្មានថានឹងកំពុងបម្រើការនៅក្នុងឆ្នាំN+1។
- #មន្ត្រីសកម្មតាមមុខងារឆ្នាំN គឺជាចំនួនមន្ត្រីសកម្មតាមមុខងារដែលកំពុងបម្រើការឆ្នាំN ដកចេញចំនួនមន្ត្រីត្រូវបានចូលនិវត្តន៍។

- #មន្ត្រីផ្ទេរចូលនិងថ្មីតាមមុខងារ គឺជាចំនួនមន្ត្រីផ្ទេរចូលពីស្ថាប័នរដ្ឋផ្សេងៗ និងគ្រូចេញបម្រើការថ្មីតាមមុខងារ។
- #មន្ត្រីផ្ទេរចេញតាមមុខងារ គឺជាចំនួនមន្ត្រីផ្ទេរចេញតាមមុខងារទៅស្ថាប័នរដ្ឋផ្សេងទៀត។
- #មន្ត្រីឈប់តាមមុខងារ គឺជាចំនួនមន្ត្រីឈប់មប្រើការនៅក្នុងក្របខ័ណ្ឌតាមមុខងារ។
- #មន្ត្រីមរណភាពតាមមុខងារ គឺជាចំនួនមន្ត្រីទទួលមរណភាពតាមមុខងារ។
- #មន្ត្រីព្យួរតាមមុខងារ គឺជាចំនួនមន្ត្រីព្យួរពីការងារមួយរយៈពេលខ្លីណាមួយតាមមុខងារ។

ប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការពីខែមករា ដល់ មីនាឆ្នាំN+1 គឺស្មើនឹងប្រាក់បំណាច់មុខងារចុងក្រោយឆ្នាំNដែរ ហើយពីខែមេសា ដល់ ធ្នូឆ្នាំN+1 គឺប្រាក់បំណាច់មុខងារនឹងត្រូវតម្លើងអនុលោមតាមសារាចរណែនាំស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំN+1។

គម្រោងចំណាយប្រាក់បំណាច់មុខងារប្រចាំឆ្នាំ ត្រូវបានគណនាដោយការគណនាគម្រោងចំណាយប្រាក់បំណាច់មុខងារប្រចាំខែតាមមុខងារពីខែមករា ដល់ ធ្នូ ឆ្នាំN+1 បន្ទាប់មកយកគម្រោងចំណាយប្រាក់បំណាច់មុខងារប្រចាំខែបូកបញ្ចូលគ្នាទាំងអស់។

### ខ. ប្រាក់ឧបត្ថម្ភមន្ត្រីចូលនិវត្តន៍

ប្រាក់ឧបត្ថម្ភមន្ត្រីចូលនិវត្តន៍ ត្រូវបានគណនាតាមរូបមន្ត៖

- **មករា ដល់ មីនា ឆ្នាំN+1**

#ប្រាក់ឧបត្ថម្ភមន្ត្រីចូលនិវត្តន៍ = (#សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN * ២៥០០) * ៨

- **មេសា ដល់ ធ្នូ ឆ្នាំN+1**

#ប្រាក់ឧបត្ថម្ភមន្ត្រីចូលនិវត្តន៍ = (#សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 * ២៥០០) * ៨

### គ. ប្រាក់ឧបត្ថម្ភមន្ត្រីរាជការមរណភាព

ប្រាក់ឧបត្ថម្ភមរណភាព ត្រូវបានគណនាតាមរូបមន្ត៖

- **មករា ដល់ មីនា ឆ្នាំN+1**

#ប្រាក់ឧបត្ថម្ភមរណភាព = (#សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN * ២៥០០) * ៦ + ១ ២០០ ០០០

- **មេសា ដល់ ធ្នូ ឆ្នាំN+1**

#ប្រាក់ឧបត្ថម្ភមរណភាព = (#សន្ទស្សន៍នៃឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 * ២៥០០) * ៦ + ១ ២០០ ០០០

## IV. **តួនាទីសន្លឹកកិច្ចការ** (Worksheet)

ប្រព័ន្ធគ្រោងបន្ទុកបុគ្គលិកមានសន្លឹកកិច្ចការមានឈ្មោះ និងតួនាទីដូចខាងក្រោម៖

- ✓ Class_Setting គឺសម្រាប់បញ្ចូលព័ត៌មានមន្ត្រីរាជការដែលត្រូវបានតម្លើងឋានន្តរស័ក្តិនិងថ្នាក់ថ្ងៃទី១X ខែមេសា ឆ្នាំN និងបញ្ចូលព័ត៌មានមន្ត្រីរាជការដែលមិនទាន់ត្រូវលក្ខខណ្ឌក្នុងការស្នើតម្លើងឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 ។
- ✓ Regional_Allowance គឺសម្រាប់បញ្ចូលព័ត៌មានមន្ត្រីរាជការដែលទទួលបានប្រាក់បំប៉នជីវភាពពិសេស។
- ✓ ETA គឺសម្រាប់បញ្ចូលព័ត៌មានមន្ត្រីរាជការដោយបិទភ្ជាប់(paste)ទិន្នន័យដែលបានថតចម្លង(copy)មកពីតារាងបៀវត្ស(ETA)ខែឧសភា ឬមិថុនា ឆ្នាំN ដោយយកតារាងបៀវត្សដែលមិនទាន់បានរំលឹកកាំប្រាក់ដែលត្រូវបានតម្លើងក្នុងថ្ងៃទី១X ខែមេសា ឆ្នាំN។
- ✓ INFO គឺសម្រាប់ផ្ទុកព័ត៌មានមន្ត្រីរាជការក្រោយពីបានកំណត់កាំប្រាក់ថ្មីនិងកាលបរិច្ឆេទតម្លើងកាំប្រាក់ចុងក្រោយ។ ប្រព័ន្ធនឹងកំណត់កំណត់កាលបរិច្ឆេទតម្លើងកាំចុងក្រោយ 14/Apr/N ចំពោះមន្ត្រីរាជការដែលត្រូវបានស្នើតម្លើងឆ្នាំN ហើយប្រព័ន្ធនឹងកំណត់កំណត់កាលបរិច្ឆេទតម្លើងកាំចុងក្រោយ 14/Apr/N+1 ចំពោះមន្ត្រីរាជការដែលនឹងមិនត្រូវលក្ខខណ្ឌក្នុងការតម្លើងកាំប្រាក់ឆ្នាំN+1 និងកំណត់ប្រាក់បំប៉នជីវភាពពិសេសចំពោះមន្ត្រីរាជការដែលបម្រើការនៅតំបន់ជួបការលំបាកនិងដាច់ស្រយាល។
- ✓ A គឺសម្រាប់បង្ហាញចំនួន និងប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការសកម្ម(កំពុងបម្រើការ)តាមឋានន្តរស័ក្តិនិងថ្នាក់ ដែលបានស្រង់ចេញពីតារាងបៀវត្ស(ETA)សុទ្ធសាធ។
- ✓ B គឺសម្រាប់បង្ហាញចំនួន និងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការសកម្ម(កំពុងបម្រើការ)តាមមុខងារដែលបានស្រង់ចេញពីតារាងបៀវត្ស(ETA)សុទ្ធសាធ។
- ✓ I គឺសម្រាប់បង្ហាញចំនួនមន្ត្រីរាជការចូលនិវត្តន៍ត្រូវផ្តាច់ប្រាក់បៀវត្ស និងបញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការស្នើសុំចូលនិវត្តន៍មុនកាលកំណត់ត្រូវផ្តាច់ប្រាក់បៀវត្សតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ។
- ✓ II គឺសម្រាប់បង្ហាញចំនួនមន្ត្រីរាជការចូលនិវត្តន៍តាមកាលកំណត់ និងស្នើសុំចូលនិវត្តន៍មុនកាលកំណត់តាមឋានន្តរស័ក្តិនិងថ្នាក់។
- ✓ III គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការផ្ទេរចូល និងចេញថ្មីតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ។
- ✓ IV គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការផ្ទេរចេញ និងឈប់ពីក្របខ័ណ្ឌតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ។
- ✓ V គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការព្យួរពីការងារតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ។
- ✓ VI គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការទទួលមរណភាពតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ។
- ✓ VII គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការផ្លាស់ប្តូរឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារដោយការប្រឡងផ្លាស់ប្តូរឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ ឬឡើងកាំប្រាក់តាមសញ្ញាបត្រ(កាំពិសេស) ឬត្រូវបានតែងតាំងមុខងារថ្មី តាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ។

- ✓ VIII គឺសម្រាប់បញ្ចូលចំនួនអ្នកគ្រូសម្រាលកូន អ្នកក្នុងបន្ទុក កូនមានអាយុចាប់ពី២០ឆ្នាំចុះ មន្ត្រីជាប់កិច្ចសន្យា គ្រូកិច្ចសន្យាចំណោះទូទៅ និងចំនួនមន្ត្រីរាជការទទួលបានប្រាក់បំប៉នជីវភាពពិសេស។
- ✓ IX គឺសម្រាប់បញ្ចូលចំនួនគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធតាមកម្មវិធីនីមួយៗ។
- ✓ Total_A គឺសម្រាប់បង្ហាញចំនួនមន្ត្រី និងបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការដែលនឹងបម្រើការតាមឋានន្តរស័ក្តិនិងថ្នាក់នៃខែនីមួយៗឆ្នាំN+1។
- ✓ Total_B គឺសម្រាប់បង្ហាញចំនួនមុខងារមន្ត្រី និងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការដែលនឹងបម្រើការតាមមុខងារនៃខែនីមួយៗឆ្នាំN+1។
- ✓ Plan គឺសម្រាប់បង្ហាញតួលេខឥណទានសរុបនៃការគ្រោងចំណាយថវិកាតាមអនុគណនី។
- ✓ T3A គឺសម្រាប់បង្ហាញតួលេខដែលបានគណនាចេញពីតារាងបៀវត្សទាំងស្រុង មានន័យថាតួលេខនេះមិនទាន់ពេញលេញសម្រាប់ផ្ញើជូនក្រសួងសេ ដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឡើងទេ អ្នកត្រូវកែសម្រួលតួលេខឱ្យបានសមស្របទៅនឹងតួលេខបម្រែបម្រួលនៃការគ្រោង។
- ✓ Status គឺសម្រាប់ត្រួតពិនិត្យស្ថានភាពនៃបញ្ចូលទិន្នន័យក្នុងសន្លឹកនីមួយៗ តើថាការបញ្ចូលទិន្នន័យមានកំហុសដែរឬទេ។
- ✓ CHILD គឺសម្រាប់បង្ហាញតួលេខ និងចំណាយលើកូនអាយុចាប់ពី២០ឆ្នាំចុះតាមឋានន្តរស័ក្តិនិងថ្នាក់ដែលបានគណនាស្រង់ចេញពីតារាងបៀវត្សទាំងស្រុង មានន័យថាមិនបានគណនាតួលេខបម្រែបម្រួលដែលអ្នកប្រើប្រាស់បានបញ្ចូលនៅឡើងទេ។
- ✓ WIFE គឺសម្រាប់បង្ហាញតួលេខ និងចំណាយលើអ្នកក្នុងបន្ទុកតាមឋានន្តរស័ក្តិនិងថ្នាក់ដែលបានគណនាស្រង់ចេញពីតារាងបៀវត្សទាំងស្រុង មានន័យថាមិនបានគណនាតួលេខបម្រែបម្រួលដែលអ្នកប្រើប្រាស់បានបញ្ចូលនៅឡើងទេ។
- ✓ POSITION គឺសម្រាប់បង្ហាញតួលេខប្រាក់បំណាច់មុខងារតាមឋានន្តរស័ក្តិនិងថ្នាក់ដែលបានគណនាស្រង់ចេញពីតារាងបៀវត្សទាំងស្រុង មានន័យថាមិនបានគណនាតួលេខបម្រែបម្រួលដែលអ្នកប្រើប្រាស់បានបញ្ចូលនៅឡើងទេ។

## V. **ការប្រើប្រាស់**

ការប្រើប្រាស់ប្រព័ន្ធគ្រោងបន្ទុកបុគ្គលិក ត្រូវអនុវត្តដូចខាងក្រោម៖

- **សន្លឹកឈ្មោះ Class_Setting**

គឺសម្រាប់បញ្ចូលព័ត៌មានមន្ត្រីរាជការ ដែលត្រូវបានតម្លើងឋានន្តរស័ក្តិនិងថ្នាក់ថ្ងៃទី១X ខែមេសា ឆ្នាំN និងបញ្ចូលព័ត៌មានមន្ត្រីរាជការដែលមិនទាន់ត្រូវលក្ខខណ្ឌក្នុងការស្នើតម្លើងឋានន្តរស័ក្តិនិងថ្នាក់ឆ្នាំN+1 ។




- សន្លឹកឈ្មោះ Regional_Allowance

គឺសម្រាប់បញ្ចូលព័ត៌មានមន្ត្រីរាជការដែលទទួលបានប្រាក់បំប៉នជីវភាពពិសេស។




- សន្លឹកឈ្មោះ ETA

គឺសម្រាប់បញ្ចូលព័ត៌មានមន្ត្រីរាជការដោយបិទភ្ជាប់(paste)ទិន្នន័យដែលបានថតចម្លង(copy)មកពីតារាងបៀវត្ស (ETA) ខែឧសភា ឬមិថុនា ឆ្នាំN ដោយយកតារាងបៀវត្សដែលមិនទាន់បានរំលឹកកាំប្រាក់ដែលត្រូវបានតម្លើងក្នុងថ្ងៃទី១X ខែមេសា ឆ្នាំN។




នៅក្នុងសន្លឹកឈ្មោះ ETA គឺមានពីរចំណុចដែលត្រូវអនុវត្តដូចខាងក្រោម៖

ទី១៖ ត្រូវចម្លង(Copy)ទិន្នន័យពីតារាងបៀវត្ស យកមកបិទភ្ជាប់(paste)នៅសន្លឹក(sheet)ឈ្មោះ ETA

ទី២៖ ចុចលើប៊ូតុងឈ្មោះ ***កំណត់កាំប្រាក់និងប្រាក់បំប៉នជីវភាពពិសេស*** ដើម្បីប្រព័ន្ធចម្លងទិន្នន័យជាស្វ័យប្រវត្តិ ពីសន្លឹក ETA ទៅបញ្ចូលនៅក្នុងសន្លឹក INFO ព្រមទាំងកំណត់កាំប្រាក់និងប្រាក់បំប៉នជីវភាពពិសេសជាស្រេច។

- **សន្លឹកឈ្មោះ INFO**

គឺសម្រាប់ផ្ទុកព័ត៌មានមន្ត្រីរាជការក្រោយពីបានកំណត់កាំប្រាក់ថ្មីនិងកាលបរិច្ឆេទតម្លើងកាំប្រាក់ចុងក្រោយ។ ប្រព័ន្ធនឹងកំណត់កំណត់កាលបរិច្ឆេទតម្លើងកាំចុងក្រោយ 14/Apr/N ចំពោះមន្ត្រីរាជការដែលត្រូវបានស្នើតម្លើងឆ្នាំN ហើយប្រព័ន្ធនឹងកំណត់កំណត់កាលបរិច្ឆេទតម្លើងកាំចុងក្រោយ 14/Apr/N+1 ចំពោះមន្ត្រីរាជការដែលនឹងមិនត្រូវលក្ខខណ្ឌក្នុងការតម្លើងកាំប្រាក់ឆ្នាំN+1 និងកំណត់ប្រាក់បំប៉នជីវភាពពិសេសចំពោះមន្ត្រីរាជការដែលបម្រើការនៅតំបន់ជួបការលំបាកនិងដាច់ស្រយាល។




នៅក្នុងសន្លឹកឈ្មោះ INFO គឺបង្ហាញព័ត៌មានចាំបាច់របស់មន្ត្រីរាជការសម្រាប់គ្រាំទ្រការគណនាគម្រោងចំណាយឆ្នាំN+1។ *ដូចនេះ អ្នកប្រើប្រាស់ត្រូវពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យនេះឱ្យបានត្រឹមត្រូវបំផុត ដូចជាជួរឈរ កម្រិតកាំ កាំបន្ទាប់ មុខងារ កាលបរិច្ឆេទចូលនិវត្តន៍ ជាដើម* ដើម្បីពិនិត្យទិន្នន័យអ្នកប្រើប្រាស់ត្រូវចុចលើសញ្ញាច្រោះ(filter)ទិន្នន័យសម្រាប់ស្វែករកទិន្នន័យមានបញ្ហាបានលឿន ដោយត្រូវអនុវត្តដូចខាងក្រោម៖

- **កម្រិតកាំ៖** ចុចសញ្ញាច្រោះត្រង់សែល(Cell) K7 -> បន្ទាប់មកចុចលើដោះធីក(Uncheck) ត្រង់ Sellect All -> រួចទាញរបា(Scroll Bar)រហូតដល់ចុងក្រោយ -> ហើយបន្ទាប់មកចុចធីក(check) លើ Blanks -> បន្ទាប់មកចុចលើប៊ូតុង OK





ករណីឃើញមានបៀវត្សមូលដ្ឋាន ប៉ុន្តែមិនមានបង្ហាញកាំប្រាក់ មានន័យថាមានកំហុស អ្នកត្រូវពិនិត្យថាតើបៀវត្សមូលដ្ឋាននេះត្រឹមត្រូវអនុលោមតាមសារាចរណែនាំលេខ ០៤ សរណន ស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ប្រសិនបើពិនិត្យឃើញថាមិនត្រឹមត្រូវអនុលោមតាមសារាចរណែនាំត្រូវកែសម្រួលឱ្យបានត្រឹមត្រូវ ប៉ុន្តែប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវអនុលោមតាមសារាចរណែនាំត្រូវជូនដំណឹងមកក្រុមការងារនៃនាយកដ្ឋានហិរញ្ញវត្ថុដើម្បីពិនិត្យលើបញ្ហាមិនប្រក្រតីនេះ។



- **កាំបន្ទាប់:** ត្រូវពិនិត្យដោយអនុវត្តដូចគ្នានឹងការពិនិត្យ **កម្រិតកាំ** ដែរ។

- **មុខងារ:** ចុចសញ្ញាព្រួញត្រង់សេល(Cell) M7 -> បន្ទាប់មកចុចលើដោះធីក(Uncheck) ត្រង់ Sellect All -> រួចទាញរបា(Scroll Bar)រហូតដល់ចុងក្រោយ -> ហើយបន្ទាប់មកចុចធីក(check) លើ #N/A-> បន្ទាប់មកចុចលើប៊ូតុង OK




ករណីឃើញមានប្រាក់បំណាច់មុខងារ ប៉ុន្តែមិនមានបង្ហាញមុខងារ មានន័យថាមានកំហុស អ្នកត្រូវពិនិត្យថាតើប្រាក់បំណាច់មុខងារនេះត្រឹមត្រូវអនុលោមតាមអនុក្រឹតលេខ៣១អនក្របក ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដែរឬទេ ប្រសិនបើពិនិត្យឃើញត្រឹមត្រូវអនុលោមតាមអនុក្រឹត្យត្រូវជូនដំណឹងមកក្រុមការងារនៃនាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីពិនិត្យលើបញ្ហាមិនប្រក្រតីនេះ។




- **កាលបរិច្ឆេទចូលនិវត្តន៍:** ចុចសញ្ញាព្រួញត្រង់សេល(Cell) N7 -> បន្ទាប់មកចុចលើដោះធីក(Uncheck) ត្រង់ Sellect All -> រួចទាញរបា(Scroll Bar)រហូតដល់ចុងក្រោយ -> ហើយបន្ទាប់មកចុចធីក(check) លើ #VALUE! -> បន្ទាប់មកចុចលើប៊ូតុង OK




ករណីឃើញ #VALUE! មានន័យថាមានកំហុស អ្នកត្រូវកែសម្រួលត្រង់ជួរឈរ **ថ្ងៃខែឆ្នាំកំណើត** ឱ្យកាលបរិច្ឆេទកំណើតត្រូវតាម Format នៃកាលបរិច្ឆេទ ដើម្បីឱ្យម៉ាស៊ីនអាចគណនាកាលបរិច្ឆេទចូលនិវត្តន៍បាន។




ករណីអ្នកប្រើប្រាស់បានរកឃើញមានកំហុសណាមួយក្នុងចំណោមកំហុសខាងលើ អ្នកត្រូវតែកែសម្រួលកំហុសឱ្យបានត្រឹមត្រូវជាមុនសិន ទើបអាចបន្តទៅបញ្ចូលទិន្នន័យផ្សេងៗទៀត។ ករណីរកមិនឃើញមានកំហុសណាមួយកើតឡើងទេ ដូចនេះអ្នកអាចបន្តទៅបញ្ចូលទិន្នន័យផ្សេងៗទៀតបានហើយ។

### សន្លឹកឈ្មោះ A

គឺសម្រាប់បង្ហាញចំនួន និងប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការសកម្ម(កំពុងបម្រើការ)តាមឋានន្តរស័ក្តិនិងថ្នាក់ ដែលបានស្រង់ចេញពីតារាងបៀវត្ស(ETA)សុទ្ធសាធ។




- **ចំណុច A** ៖ ត្រូវបញ្ចូលចំនួនមន្ត្រីរាជការតាមឋានន្តរស័ក្តិនិងថ្នាក់ ដែលបានបម្រើការក្នុងក្របខ័ណ្ឌរដ្ឋបានច្រើនជាង៣០ឆ្នាំបានស្នើសុំចូលនិវត្តន៍មុនកាលកំណត់ ដែលនឹងត្រូវផ្តាច់ចេញពីតារាងបៀវត្សនៅខែមករា ឆ្នាំN+1។
- **ចំណុច B** ៖ ត្រូវបញ្ចូលចំនួនមន្ត្រីរាជការតាមមុខងារ ដែលបានបម្រើការក្នុងក្របខ័ណ្ឌរដ្ឋបានច្រើនជាង៣០ឆ្នាំបានស្នើសុំចូលនិវត្តន៍មុនកាលកំណត់ ដែលនឹងត្រូវផ្តាច់ចេញពីតារាងបៀវត្សនៅខែមករា ឆ្នាំN+1។ រីឯខែផ្សេងទៀត គឺការបញ្ចូលទិន្នន័យមានលក្ខណៈដូចគ្នានឹងខែមករាដែរ។

### សន្លឹកឈ្មោះ II

គឺសម្រាប់បង្ហាញចំនួនមន្ត្រីរាជការចូលនិវត្តន៍តាមកាលកំណត់ និងស្នើសុំចូលនិវត្តន៍មុនកាលកំណត់តាមឋានន្តរស័ក្តិនិងថ្នាក់នៃខែនីមួយៗ ឆ្នាំN+1។



### សន្លឹកឈ្មោះ III

គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការផ្ទេរចូល និងចេញថ្មីតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារនៃខែនីមួយៗ ឆ្នាំN+1។




- **ចំណុច A ៖** ត្រូវបញ្ចូលចំនួនមន្ត្រីរាជការផ្ទេរចូល និងចូលបម្រើការថ្មីតាមឋានន្តរស័ក្តិនិងថ្នាក់
- **ចំណុច B ៖** ត្រូវបញ្ចូលចំនួនមន្ត្រីរាជការផ្ទេរចូល និងចូលបម្រើការថ្មីតាមមុខងារ

រីឯខែផ្សេងទៀត គឺការបញ្ចូលទិន្នន័យមានលក្ខណៈដូចគ្នានឹងខែមករាដែរ។ ប៉ុន្តែ **ខែមករា និងខែតុលា** ត្រូវមានបំរុងប្រយ័ត្នខ្ពស់ក្នុងការបញ្ចូលទិន្នន័យ ដោយមានលក្ខណៈពិសេសដូចខាងក្រោម៖

- **ខែមករា៖** ចំពោះទិន្នន័យត្រូវបញ្ចូលនៅក្នុងខែមករា ត្រូវគិតចាប់តាំងពីខែបន្ទាប់ពីយកព័ត៌មានពីតារាងបៀវត្សមកបញ្ចូលក្នុងសន្លឹក ETA នៃប្រព័ន្ធគ្រោងបន្ទុកបុគ្គលិក ទាំងចំនួនមន្ត្រីរាជការផ្ទេរចូល និងគ្រូបង្រៀនចេញបម្រើការថ្មី។ ពិសេសនៅខែតុលា ឆ្នាំN ជាទូទៅមានគ្រូបង្រៀនចេញថ្មីទៅកាន់គ្រប់មន្ទីររាជធានី-ខេត្ត ដូចនេះត្រូវយកតួលេខគ្រូទាំងនេះមកបញ្ចូលនៅខែមករា ឆ្នាំN+1។ រីឯការផ្លាស់ចូលក៏អាចមានច្រើនដែរ នៅកំឡុងបវេសនកាល(ខែសីហា និងកញ្ញា)នៃឆ្នាំសិក្សា(ត្រូវនឹងឆ្នាំNនៃឆ្នាំថវិកា) ត្រូវយកតួលេខនេះមកបញ្ចូលនៅខែមករា ឆ្នាំN+1ដែរ ករណីពួកគាត់នឹងត្រូវទទួលបានប្រាក់បៀវត្សពីមន្ទីររាជធានី-ខេត្ត(អង្គភាពថ្មី)ចាប់ពីខែមករា ឆ្នាំN+1 ឬបណ្តាមុនខែនៃឆ្នាំN ប៉ុន្តែករណីពួកគាត់នៅមិនទាន់ទទួលបានប្រាក់បៀវត្សបើកជូនពីមន្ទីររាជធានី-ខេត្ត(អង្គភាពថ្មី) មិនត្រូវយកតួលេខនេះមកបញ្ចូលក្នុងខែមករា ឆ្នាំN+1ទេ ត្រូវយកតួលេខនេះ ទៅបញ្ចូលក្នុងខែណាមួយ ដែលមន្ទីររាជធានី-ខេត្ត(អង្គភាពថ្មី)មានលទ្ធភាពបើកប្រាក់បៀវត្សជូនពួកគាត់។
- **ខែតុលា៖** ជាទូទៅ គ្រូបង្រៀនចេញថ្មីនឹងត្រូវចូលបម្រើការនៅខែតុលា ឆ្នាំN+1 តួលេខនេះអាចត្រូវបានយកមកបញ្ចូល ឬមិនបញ្ចូល អាស្រ័យលើសាមីមន្ទីររាជធានី-ខេត្តនីមួយៗអាចបើកបៀវត្សជូនពួកគាត់

ទាន់នៅក្នុងឆ្នាំN+1ដែរឬទេ។ ករណី មន្ទីររាជធានី-ខេត្តអាចបើកបៀវត្សជូនពួកគាត់ទាន់នៅក្នុងឆ្នាំN+1 ត្រូវបញ្ចូលតួលេខគ្រូបង្រៀនចេញថ្មី ផ្ទុយទៅវិញគឺមិនត្រូវបញ្ចូលតួលេខនេះទេ។

### សន្លឹកឈ្មោះ IV

គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការផ្ទេរចេញ និងឈប់ពីក្របខ័ណ្ឌតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារនៃខែនីមួយៗ ឆ្នាំN+1។




### សន្លឹកឈ្មោះ V

គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការព្យួរពីការងារតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារនៃខែនីមួយៗ ឆ្នាំN+1។



## ✚ សន្លឹកឈ្មោះ VI

គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការទទួលមរណភាពតាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារនៃខែនីមួយៗ ឆ្នាំN+1។




## ✚ សន្លឹកឈ្មោះ VII

គឺសម្រាប់បញ្ចូលចំនួនប៉ាន់ស្មានមន្ត្រីរាជការផ្លាស់ប្តូរឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារដោយការប្រឡងផ្លាស់ប្តូរឋានន្តរស័ក្តិ និងថ្នាក់ និងមុខងារ ឬឡើងកាំប្រាក់តាមសញ្ញាបត្រ(កាំពិសេស) ឬត្រូវបានតែងតាំងមុខងារថ្មី តាមឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារនៃខែនីមួយៗ ឆ្នាំN+1។




## ✚ សន្លឹកឈ្មោះ VIII

គឺសម្រាប់បញ្ចូលចំនួនអ្នកគ្រូសម្រាលកូន អ្នកក្នុងបន្ទុក កូនមានអាយុចាប់ពី២០ឆ្នាំចុះ មន្ត្រីជាប់កិច្ចសន្យា គ្រូកិច្ចសន្យាចំណេះទូទៅ និងចំនួនមន្ត្រីរាជការទទួលបានប្រាក់បំប៉នជីវភាពពិសេស។

ផ្នែក **ក** គឺត្រូវបញ្ចូលទិន្នន័យចំនួនអ្នកគ្រូសម្រាលកូន កូនអាយុ២០ឆ្នាំចុះ និងអ្នកក្នុងបន្ទុក។



**ទិន្នន័យគ្រួសារ មន្ត្រីជាប់កិច្ចសន្យា គ្រូកិច្ចសន្យាចំណេះទូទៅ និងប្រាក់បំប៉នជីវភាពពិសេស**

**ក). ទិន្នន័យគ្រួសារ**

| ល | ខែ | មន្ត្រីសកម្មនៃតារាងបៀវត្ស | | បម្រែបម្រួលស្ថានភាពគ្រួសារមន្ត្រីសកម្មនៃតារាងបៀវត្ស | | | | | មន្ត្រីរាជការផ្ទេរចូលនិងថ្មី | | | មន្ត្រីរាជការផ្ទេរចេញនិងឈប់ពីក្របខ័ណ្ឌ | | | មន្ត្រីរាជការព្យួរពីការងារថ្មី | | | មន្ត្រីរាជការព្យួរពីការងារចូលបម្រើការវិញ | | | មន្ត្រីរាជការទទួលមរណៈភាព | | | មន្ត្រីរាជការចូលនិវត្តន៍ផ្ទាត់ពីតារាងបៀវត្ស | | | ស្ថានភាពគ្រួសារ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំនួន | ចំនួនអ្នកគ្រូសម្រាលកូន | ចំនួនអ្នកក្នុងបន្ទុកថ្មី | កូនមានអាយុចាប់ពី២០ឆ្នាំចុះស្នើសុំថ្មី | កូនមានអាយុចាប់ពី២០ឆ្នាំចុះផុតអាយុ | ចំនួន | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំនួន | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំនួន | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំនួន | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំនួន | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំនួន | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំនួនអ្នកគ្រូសម្រាលកូន | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | កូនមានអាយុចាប់ពី២០ឆ្នាំចុះ |
| ១ | មករា | 505 | 1,511 | 1,894 | | | | | - | | | - | | | - | | | - | | | - | | | 1 | - | - | - | 505 | 1,511 |
| ២ | កុម្ភៈ | 505 | 1,511 | 1,892 | | | | | - | | | - | | | - | | | - | | | - | | | 2 | - | 1 | - | 505 | 1,511 |
| ៣ | មីនា | 505 | 1,510 | 1,890 | | | | | 2 | | | - | | | - | | | - | | | - | | | 2 | 1 | 1 | - | 505 | 1,510 |
| ៤ | មេសា | 504 | 1,510 | 1,889 | | | | | - | | | - | | | - | | | - | | | - | | | 1 | 1 | 1 | - | 504 | 1,510 |
| ៥ | ឧសភា | 504 | 1,509 | 1,887 | | | | | - | | | - | | | - | | | - | | | - | | | 2 | - | 1 | - | 504 | 1,509 |
| ៦ | មិថុនា | 504 | 1,509 | 1,886 | | | | | - | | | - | | | - | | | - | | | - | | | 1 | - | - | - | 504 | 1,509 |
| ៧ | កក្កដា | 504 | 1,509 | 1,886 | | | | | - | | | - | | | - | | | - | | | - | | | - | - | - | - | 504 | 1,509 |
| ៨ | សីហា | 504 | 1,509 | 1,885 | | | | | - | | | - | | | - | | | - | | | - | | | 1 | 1 | 1 | - | 504 | 1,509 |
| ៩ | កញ្ញា | 503 | 1,508 | 1,882 | | | | | - | | | - | | | - | | | - | | | - | | | 3 | 1 | 1 | - | 503 | 1,508 |
| ១០ | តុលា | 503 | 1,508 | 1,882 | | | | | - | | | - | | | - | | | - | | | - | | | - | - | - | - | 503 | 1,508 |
| ១១ | វិច្ឆិកា | 503 | 1,508 | 1,882 | | | | | - | | | - | | | - | | | - | | | - | | | - | - | 1 | - | 503 | 1,508 |
| ១២ | ធ្នូ | 503 | 1,507 | 1,881 | | | | | - | | | - | | | - | | | - | | | - | | | 1 | - | 1 | - | 503 | 1,507 |
| សរុប | | 6,047 | 18,109 | 22,636 | - | - | - | - | 2 | - | - | - | - | - | - | - | - | - | - | - | - | - | - | 14 | 4 | 8 | - | 6,047 | 18,109 |

**ខ). មន្ត្រីជាប់កិច្ចសន្យា**( 64041 )

Class_Setting | Regional_Allowance | ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CH ...

ផ្នែក **ខ** គឺត្រូវបញ្ចូលចំនួនមន្ត្រីជាប់កិច្ចសន្យា ដែលនឹងត្រូវបម្រើការឆ្នាំN+1។

ផ្នែក **គ** គឺត្រូវបញ្ចូលចំនួនគ្រូកិច្ចសន្យាចំណេះទូទៅតាមប្រភេទជាគ្រូចូលនិវត្តន៍ ឬសិស្ស និស្សិត ព្រមទាំងគ្រូបំពេញភារកិច្ចថ្នាក់គួបពីរឬបីកម្រិត និងបង្រៀនពីរវេន។



**ទិន្នន័យគ្រួសារ មន្ត្រីជាប់កិច្ចសន្យា គ្រូកិច្ចសន្យាចំណេះទូទៅ និងប្រាក់បំប៉នជីវភាពពិសេស**

**ខ). មន្ត្រីជាប់កិច្ចសន្យា**( 64041 )

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួន | | - | - | - | - | - | - | - | - | - | - | - | |
| ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - |

**គ). គ្រូកិច្ចសន្យាចំណេះទូទៅ និងភារកិច្ចបន្ថែម**

| ចំណាយ | បរិយាយ | វិច្ឆិកាឆ្នាំN | ធ្នូឆ្នាំN | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គ្រូបង្រៀនពីរវេន (១០០%)(64023) | #គ្រូ | | | | | | | | | | | | | | | |
| | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| គ្រូកិច្ចសន្យាចំណេះទូទៅគ្រូចូលនិវត្តន៍ (៩០%)(64041) | #គ្រូ | | | | | | | | | | | | | | | |
| | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| គ្រូកិច្ចសន្យាចំណេះទូទៅសិស្ស និស្សិត (៨០%)(64041) | #គ្រូ | | | | | | | | | | | | | | | |
| | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| គ្រូបង្រៀនថ្នាក់គួបបីកម្រិត (៨០%)(64023) | #គ្រូ | | | | | | | | | | | | | | | |
| | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| គ្រូបង្រៀនថ្នាក់គួបពីរកម្រិត(៦០%)(64023) | #គ្រូ | | | | | | | | | | | | | | | |
| | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| សរុប | | | | | | | | | | | | | | | | - |

Class_Setting | Regional_Allowance | ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CH ...

ផ្នែក **ឃ** គឺត្រូវបញ្ចូលចំនួនបម្រែបម្រួលមន្ត្រីរាជការទទួលបានប្រាក់បំប៉នជីវភាពពិសេស

| ទិតាជន៍គ្រួសារ មន្ត្រីជាប់កិច្ចសន្យា គ្រូកិច្ចសន្យាចំណេះទូទៅ និងប្រាក់បំប៉នជីវភាពពិសេស | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ឃ). ប្រាក់បំប៉នជីវភាពពិសេស**( 64025 ) | | | | | | | | | | | | | | |
| **ចំណាយ** | **បរិយាយ** | **មករា** | **កុម្ភៈ** | **មីនា** | **មេសា** | **ឧសភា** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** | **សរុប** |
| តំបន់ជួបការលំបាក ( ៨០ ០០០៛) | ស្រង់ពីតារាងបៀវត្ស | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | |
| | ប្រែប្រួលឆ្នាំN+1 | | | | | | | | | | | | | |
| | #ថវិកា | 160,000 | 160,000 | 160,000 | 160,000 | 160,000 | 160,000 | 160,000 | 160,000 | 160,000 | 160,000 | 160,000 | 160,000 | **1,920,000** |
| តំបន់ដាច់ស្រយាល ប្រភេទ១ ( ១០០ ០០០៛) | ស្រង់ពីតារាងបៀវត្ស | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | |
| | ប្រែប្រួលឆ្នាំN+1 | | | | | | | | | | | | | |
| | #ថវិកា | 500,000 | 500,000 | 500,000 | 500,000 | 500,000 | 500,000 | 500,000 | 500,000 | 500,000 | 500,000 | 500,000 | 500,000 | **6,000,000** |
| តំបន់ដាច់ស្រយាល ប្រភេទ២ ( ១២០ ០០០៛) | ស្រង់ពីតារាងបៀវត្ស | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | |
| | ប្រែប្រួលឆ្នាំN+1 | | | | | | | | | | | | | |
| | #ថវិកា | 240,000 | 240,000 | 240,000 | 240,000 | 240,000 | 240,000 | 240,000 | 240,000 | 240,000 | 240,000 | 240,000 | 240,000 | **2,880,000** |
| **សរុប** | | | | | | | | | | | | | | **10,800,000** |

Class_Setting | Regional_Allowance | ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CH...

## សន្លឹកឈ្មោះ IX

គឺសម្រាប់បញ្ចូលចំនួនគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធតាមកម្មវិធីនីមួយៗ។

| **គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ**( 64041 ) | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ល** | **មុខចំណាយ** | **បរិយាយ** | **វិច្ឆិកាឆ្នាំN** | **ធ្នូឆ្នាំN** | **មករា** | **កុម្ភៈ** | **មីនា** | **មេសា** | **ឧសភា** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** | **សរុប** |
| ១ | កម្មវិធីសមមូលបឋមសិក្សា( ១០ខែ )គ្រូចូលនិវត្តន៍( ៦០% ) | #គ្រូ | | | | | | | | | | | | | | | |
| | | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| ២ | កម្មវិធីសមមូលបឋមសិក្សា( ១០ខែ )សិស្ស និស្សិត( ៥០% ) | #គ្រូ | | | | | | | | | | | | | | | |
| | | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| ៣ | កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ( ៨ខែ )គ្រូចូលនិវត្តន៍( ៦០% ) | #គ្រូ | | | | | | | | | | | | | | | |
| | | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| ៤ | កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ( ៨ខែ )សិស្ស និស្សិត( ៥០% ) | #គ្រូ | | | | | | | | | | | | | | | |
| | | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| ៥ | កម្មវិធីចូលរៀនឡើងវិញ( ២ខែ )គ្រូចូលនិវត្តន៍( ៩០% ) | #គ្រូ | | | | | | | | | | | | | | | |
| | | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| ៦ | កម្មវិធីចូលរៀនឡើងវិញ( ២ខែ )សិស្ស និស្សិត( ៨០% ) | #គ្រូ | | | | | | | | | | | | | | | |
| | | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| ៧ | កម្មវិធីបង្កើនប្រាក់ចំណូល( ១ ទៅ ៦ខែ គ្រូជំនាញ១០០% ) | #គ្រូ | | | | | | | | | | | | | | | |
| | | #ថវិកា | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| **សរុប** | | | | | | | | | | | | | | | | | - |

... | ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## សន្លឹកឈ្មោះ Total_A

គឺសម្រាប់បង្ហាញចំនួនមន្ត្រី និងបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការដែលនឹងបម្រើការតាមឋានន្តរស័ក្តិនិងថ្នាក់នៃខែនីមួយៗ ឆ្នាំN+1។

**គម្រោងចំណាយប្រាក់បៀវត្សមូលដ្ឋានតាមខែនៃឆ្នាំN+1**

| ខែ | របខ័ណ្ឌ | នន្តរស | ចំនួនមន្ត្រីរាជការសកម្មតាមឋានន្តរស័ក្តិ និងថ្នាក់ ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ | សរុប | គម្រោងចំណាយបៀវត្សមូលដ្ឋានមន្ត្រីរាជការសកម្មតាមឋានន្តរស័ក្តិ និងថ្នាក់ ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មករា | ក | ១ | | | | | 206 | 69 | 4 | - | - | - | 279 | | | | | 237,415,000 | 82,627,500 | 4,960,000 | - | - | - | 325,002,500 |
| | | ២ | | | | | | | 37 | 55 | 30 | 153 | 275 | | | | | | | 36,445,000 | 56,375,000 | 31,950,000 | 169,447,500 | 294,217,500 |
| | | ៣ | | | | | | | 31 | 65 | 36 | 18 | 150 | | | | | | | 26,737,500 | 57,525,000 | 32,760,000 | 17,055,000 | 134,077,500 |
| | ខ | ១ | | | | | 6 | - | - | - | - | - | 6 | | | | | 5,895,000 | - | - | - | - | - | 5,895,000 |
| | | ២ | | | | | | | 59 | 79 | 234 | 61 | 433 | | | | | | | 50,740,000 | 70,705,000 | 215,865,000 | 57,950,000 | 395,260,000 |
| | | ៣ | | | | | | | 32 | 129 | 128 | 85 | 374 | | | | | | | 24,000,000 | 99,330,000 | 101,760,000 | 70,337,500 | 295,427,500 |
| | គ | គ្មាន | 6 | 15 | 7 | 311 | 37 | 1 | - | - | - | - | 377 | 3,975,000 | 10,275,000 | 4,970,000 | 229,362,500 | 28,397,500 | 802,500 | - | - | - | - | 277,782,500 |
| | | | សរុប | | | | | | | | | | 1,894 | សរុប | | | | | | | | | | 1,727,662,500 |
| កុម្ភៈ | ក | ១ | | | | | 206 | 69 | 4 | - | - | - | 279 | | | | | 237,415,000 | 82,627,500 | 4,960,000 | - | - | - | 325,002,500 |
| | | ២ | | | | | | | 37 | 55 | 30 | 153 | 275 | | | | | | | 36,445,000 | 56,375,000 | 31,950,000 | 169,447,500 | 294,217,500 |
| | | ៣ | | | | | | | 31 | 65 | 36 | 18 | 150 | | | | | | | 26,737,500 | 57,525,000 | 32,760,000 | 17,055,000 | 134,077,500 |
| | ខ | ១ | | | | | 5 | - | - | - | - | - | 5 | | | | | 4,912,500 | - | - | - | - | - | 4,912,500 |
| | | ២ | | | | | | | 59 | 79 | 234 | 61 | 433 | | | | | | | 50,740,000 | 70,705,000 | 215,865,000 | 57,950,000 | 395,260,000 |
| | | ៣ | | | | | | | 32 | 129 | 127 | 85 | 373 | | | | | | | 24,000,000 | 99,330,000 | 100,965,000 | 70,337,500 | 294,632,500 |
| | គ | គ្មាន | 6 | 15 | 7 | 311 | 37 | 1 | - | - | - | - | 377 | 3,975,000 | 10,275,000 | 4,970,000 | 229,362,500 | 28,397,500 | 802,500 | - | - | - | - | 277,782,500 |
| | | | សរុប | | | | | | | | | | 1,892 | សរុប | | | | | | | | | | 1,725,885,000 |
| មីនា | ក | ១ | | | | | 206 | 69 | 4 | - | - | - | 279 | | | | | 237,415,000 | 82,627,500 | 4,960,000 | - | - | - | 325,002,500 |
| | | ២ | | | | | | | 37 | 55 | 30 | 153 | 275 | | | | | | | 36,445,000 | 56,375,000 | 31,950,000 | 169,447,500 | 294,217,500 |
| | | ៣ | | | | | | | 31 | 65 | 36 | 18 | 150 | | | | | | | 26,737,500 | 57,525,000 | 32,760,000 | 17,055,000 | 134,077,500 |
| | | ១ | | | | | 5 | - | 2 | - | - | - | 7 | | | | | 4,912,500 | - | 2,105,000 | - | - | - | 7,017,500 |

... ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## ✦ សន្លឹកឈ្មោះ Total_B

គឺសម្រាប់បង្ហាញចំនួនមុខងារ និងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការដែលនឹងបម្រើការតាមមុខងារនៃខែនីមួយៗ ឆ្នាំN+1។

**គម្រោងចំណាយប្រាក់បំណាច់មុខងារតាមខែនៃឆ្នាំN+1**

| ខែ | បរិយាយ | សរុប | អនុប្រធាននាយកដ្ឋាន/អនុប្រ.ផ្នែក/ន.សាលាមធ្យមសិក្សាគរុ.មត្តេយ្យមជ្ឈិម/ន.សាលាគរុ.និងវិក្រឹតការខេត្ត/ន.រងមជ្ឈ. | អនុប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា/ន.រងវិ.ជាតិអប់រំកាយនិងកីឡា/សាស្ត្រាចារ្យជំនួយ | ទីប្រឹក្សាឋានៈស្មើអគ្គនាយក/ជំនួយការឋានៈស្មើអគ្គនាយក/គ្រូបង្រៀនកម្រិតមូលដ្ឋានឋានៈស្មើអគ្គនាយក | ប្រធានការ.ថ្នាក់កណ្តាលឬមន្ត្រីគ្រប់គ្រងរដ្ឋបាលឬមន្ត្រីបច្ចេកទេសឋានៈស្មើអនុប្រធាននាយកដ្ឋាន | គ្រូឧទ្ទេសឧត្តមសិក្សា (ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | នាយកវិទ្យាល័យ | ទីប្រឹក្សាឋានៈស្មើអគ្គនាយករង | ទីប្រឹក្សាឋានៈស្មើប្រធាននាយកដ្ឋាន/ជំនួយការឋានៈស្មើប្រធាននាយកដ្ឋាន/នាយកអនុវិទ្យាល័យ/គ្រូ | ទីប្រឹក្សាឋានៈស្មើអគ្គនាយករង | ប្រធានដេប៉ាតឺម៉ង់/នាយកសាលាបឋមសិក្សា/អធិការមធ្យមសិក្សា/គ្រូឧទ្ទេសមធ្យមសិក្សាទុតិយភូមិ(ក្រប | ទីប្រឹក្សាឋានៈស្មើប្រ.ដ្ឋាន/អនុប្រធានដេប៉ាតឺម៉ង់/ន.សាលាមត្តេយ្យសិក្សា/គ្រូឧទ្ទេសកម្រិតមូលដ្ឋាន(ក្របខណ្ឌគ្រូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មករា | ចំនួន | 1,894 | 1 | - | - | - | - | 5 | - | 3 | - | 26 | 1 |
| | ប្រាក់បំណាច់មុខងារ | 1,180,850,000 | 830,000 | - | - | - | - | 3,800,000 | - | 2,190,000 | - | 18,460,000 | 700,000 |
| កុម្ភៈ | ចំនួន | 1,892 | 1 | - | - | - | - | 5 | - | 3 | - | 26 | 1 |
| | ប្រាក់បំណាច់មុខងារ | 1,179,610,000 | 830,000 | - | - | - | - | 3,800,000 | - | 2,190,000 | - | 18,460,000 | 700,000 |
| មីនា | ចំនួន | 1,890 | 1 | - | - | - | - | 5 | - | 3 | - | 26 | 1 |
| | ប្រាក់បំណាច់មុខងារ | 1,178,350,000 | 830,000 | - | - | - | - | 3,800,000 | - | 2,190,000 | - | 18,460,000 | 700,000 |
| មេសា | ចំនួន | 1,889 | 1 | - | - | - | - | 5 | - | 3 | - | 26 | 1 |
| | ប្រាក់បំណាច់មុខងារ | 1,177,730,000 | 830,000 | - | - | - | - | 3,800,000 | - | 2,190,000 | - | 18,460,000 | 700,000 |
| ឧសភា | ចំនួន | 1,887 | 1 | - | - | - | - | 5 | - | 3 | - | 25 | 1 |
| | ប្រាក់បំណាច់មុខងារ | 1,176,390,000 | 830,000 | - | - | - | - | 3,800,000 | - | 2,190,000 | - | 17,750,000 | 700,000 |
| មិថុនា | ចំនួន | 1,886 | 1 | - | - | - | - | 5 | - | 3 | - | 25 | 1 |
| | ប្រាក់បំណាច់មុខងារ | 1,175,770,000 | 830,000 | - | - | - | - | 3,800,000 | - | 2,190,000 | - | 17,750,000 | 700,000 |
| | ចំនួន | 1,886 | 1 | - | - | - | - | 5 | - | 3 | - | 25 | 1 |

... ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## ✦ សន្លឹកឈ្មោះ Plan

គឺសម្រាប់បង្ហាញតួលេខឥណទានសរុបនៃការគ្រោងចំណាយថវិកាតាមអនុគណនី។

**គម្រោងចំណាយបន្ទុកបុគ្គលិក**

| ល | អនុគណនី | បរិយាយ | គម្រោងចំណាយ |
|---|---|---|---|
| 1 | 64021 | បៀវត្សមូលដ្ឋាន | 21,233,690,000 |
| 2 | 64022 | ប្រាក់បំណាច់មុខងារ | 14,111,610,000 |
| 3 | 64023 | ប្រាក់បំណាច់ម៉ោងបន្ថែម | - |
| 4 | 64025 | ប្រាក់បំប៉នជីវភាពពិសេស | 10,800,000 |
| 5 | 64041 | បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា | - |
| 6 | 64052 | អ្នកសម្រាលកូន | - |
| 7 | 64053 | មរណៈភាព | - |
| 8 | 64054 | ឧបត្ថម្ភនិវត្តជន | 96,960,000 |
| 9 | 64061 | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | 181,090,000 |
| 10 | 64063 | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 90,705,000 |
| 11 | 64981 | បន្ទុកបុគ្គលិកផ្សេងៗទៀត | - |

USER:
តួលេខនេះ គឺគណនាតែប្រាក់បំណាច់ម៉ោងបន្ថែមសម្រាប់បំពេញភារៈកិច្ចបង្រៀនថ្នាក់គួបពីរឬបីកម្រិត និងពីរវេនប៉ុណ្ណោះ ដូច្នេះអ្នកត្រូវគណនាប្រាក់បំណាច់ម៉ោងបន្ថែមផ្សេងទៀត។

ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## ✚ សន្លឹកឈ្មោះ T3A

គឺសម្រាប់បង្ហាញតួលេខដែលបានគណនាចេញពីតារាងបៀវត្ស មានន័យថាតួលេខនេះមិនទាន់ពេញលេញសម្រាប់ផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឡើងទេ អ្នកត្រូវកែសម្រួលតួលេខឱ្យបានសមស្របទៅនឹងតួលេខបម្រែបម្រួលនៃការគ្រោង។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**គម្រោងថវិកាឆ្នាំ២០២១**
**គម្រោងបន្ទុកបុគ្គលិកក្របខ័ណ្ឌ និងមិនមែនក្របខ័ណ្ឌ**

**តារាង ៣"ក"**

| កាំប្រាក់ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | | | | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួនមន្ត្រី (នាក់) | ចំនួនមន្ត្រី (នាក់) | សរុបទឹកប្រាក់ | បៀវត្សមូលដ្ឋាន | ប្រាក់បំណាច់មុខងារ | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | អ្នកក្នុងបន្ទុក | |
| **សរុបរួមៈ** | **1,894** | **1,883** | **35,717.5** | **21,233.7** | **14,212.1** | **181.1** | **90.7** | Ok |
| **បុគ្គលិកអចិន្ត្រៃយ៍** | **1,894** | **1,883** | **35,717.5** | **21,233.7** | **14,212.1** | **181.1** | **90.7** | Ok |
| **សរុប ក** | **704** | **701** | **14,732.5** | **9,273.4** | **5,341.6** | **77.7** | **39.7** | Ok |
| **ក.១** | **279** | **427** | **8,605.0** | **5,558.3** | **2,972.5** | **46.0** | **28.2** | Ok |
| ក.១.១ | 0 | 0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | - |
| ក.១.២ | 0 | 0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | - |
| ក.១.៣ | 0 | 3 | 52.0 | 34.6 | 17.1 | 0.0 | 0.3 | Ok |
| ក.១.៤ | 4 | 69 | 1,210.3 | 791.1 | 409.9 | 5.1 | 4.2 | Ok |
| ក.១.៥ | 69 | 205 | 3,797.4 | 2,463.3 | 1,301.4 | 19.3 | 13.5 | Ok |

USER:
តួលេខនេះ គឺគ្រាន់តែគណនាមកពីតារាងបៀវត្សប៉ុណ្ណោះ អ្នកត្រូវកែសម្រួលតួលេខឱ្យស្របជាមួយបំរែបំរួលជាក់ស្តែងបន្ថែមទៀត

ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## ✚ សន្លឹកឈ្មោះ Status

គឺសម្រាប់ត្រួតពិនិត្យស្ថានភាពនៃបញ្ចូលទិន្នន័យក្នុងសន្លឹកនីមួយៗ។ ឧទាហរណ៍៖ នៅក្នុងរូបខាងក្រោមនេះ បានបង្ហាញថា នៅក្នុងសន្លឹកឈ្មោះ III និងខែមីនា មានកំហុសនៃការបញ្ចូលទិន្នន័យ ដូចនេះអ្នកត្រូវទៅពិនិត្យឡើងវិញលើការបញ្ចូលទិន្នន័យខែមីនា។

**តារាងស្ថានភាពនៃការរៀបចំគម្រោងចំណាយ**

| ល | ខែ | ផ្ទាច់ពីតារាងបៀវត្ស (I) | ផ្ទេរចូលនិងថ្មី (III) | ផ្ទេរចេញ និងឈប់ពីក្របខ័ណ្ឌ (IV) | ព្យួរពីការងារថ្មីនិងចូលបម្រើការវិញ (V): ព្យួរពីការងារថ្មី | ព្យួរពីការងារថ្មីនិងចូលបម្រើការវិញ (V): ព្យួរចូលបម្រើការវិញ | ទទួលមរណៈភាព (VI) | បម្រែបម្រួលឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ (VII): ឋានន្តរស័ក្តិនិងថ្នាក់ | បម្រែបម្រួលឋានន្តរស័ក្តិនិងថ្នាក់ និងមុខងារ (VII): មុខងារ |
|---|---|---|---|---|---|---|---|---|---|
| ១ | មករា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ២ | កុម្ភៈ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ៣ | មីនា | ត្រឹមត្រូវ | មិនទាន់ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ៤ | មេសា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ៥ | ឧសភា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ៦ | មិថុនា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ៧ | កក្កដា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ៨ | សីហា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ៩ | កញ្ញា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ១០ | តុលា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ១១ | វិច្ឆិកា | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |
| ១២ | ធ្នូ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ | ត្រឹមត្រូវ |

... ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## សន្លឹកឈ្មោះ CHILD

គឺសម្រាប់បង្ហាញតួលេខនិងចំណាយលើកូនអាយុចាប់ពី២០ឆ្នាំចុះតាមឋានន្តរស័ក្តិនិងថ្នាក់ដែលបានគណនាស្រង់ចេញពីតារាងបៀវត្សទាំងស្រុង មានន័យថាមិនបានគណនាតួលេខបម្រែបម្រួលដែលអ្នកប្រើប្រាស់បានបញ្ចូលនៅឡើងទេ។

**តារាងសម្រាប់កូនមានអាយុចាប់ពី២០ឆ្នាំចុះពីតារាងបៀវត្ស**

| ខែ | ក្របខ័ណ្ឌ | ឋានន្តរស័ក្តិ | ចំនួនមន្ត្រីរាជការសកម្មតាមឋានន្តរស័ក្តិ និងថ្នាក់: ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ | សរុប | គម្រោងចំណាយបៀវត្សមូលដ្ឋានមន្ត្រីរាជការសកម្មតាមឋានន្តរស័ក្តិ និងថ្នាក់: ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មករា | ក | ១ | | | | | 195 | 57 | - | - | - | - | 252 | | | | | 1,950,000 | 570,000 | - | - | - | - | 2,520,000 |
| | | ២ | | | | | | | 38 | 65 | 43 | 177 | 323 | | | | | | | 380,000 | 650,000 | 430,000 | 1,770,000 | 3,230,000 |
| | | ៣ | | | | | | | 8 | 34 | 18 | 13 | 73 | | | | | | | 80,000 | 340,000 | 180,000 | 130,000 | 730,000 |
| | ខ | ១ | | | | | 4 | - | - | - | - | - | 4 | | | | | 40,000 | - | - | - | - | - | 40,000 |
| | | ២ | | | | | | | 67 | 76 | 180 | 50 | 373 | | | | | | | 670,000 | 760,000 | 1,800,000 | 500,000 | 3,730,000 |
| | | ៣ | | | | | | | 23 | 63 | 100 | 63 | 249 | | | | | | | 230,000 | 630,000 | 1,000,000 | 630,000 | 2,490,000 |
| | គ | គ្មាន | - | 10 | 2 | 186 | 39 | - | - | - | - | - | 237 | - | 100,000 | 20,000 | 1,860,000 | 390,000 | - | - | - | - | - | 2,370,000 |
| | | | សរុប | | | | | | | | | | 1,511 | សរុប | | | | | | | | | | 15,110,000 |
| កុម្ភៈ | ក | ១ | | | | | 195 | 57 | - | - | - | - | 252 | | | | | 1,950,000 | 570,000 | - | - | - | - | 2,520,000 |
| | | ២ | | | | | | | 38 | 65 | 43 | 177 | 323 | | | | | | | 380,000 | 650,000 | 430,000 | 1,770,000 | 3,230,000 |
| | | ៣ | | | | | | | 8 | 34 | 18 | 13 | 73 | | | | | | | 80,000 | 340,000 | 180,000 | 130,000 | 730,000 |
| | ខ | ១ | | | | | 4 | - | - | - | - | - | 4 | | | | | 40,000 | - | - | - | - | - | 40,000 |
| | | ២ | | | | | | | 67 | 76 | 180 | 50 | 373 | | | | | | | 670,000 | 760,000 | 1,800,000 | 500,000 | 3,730,000 |
| | | ៣ | | | | | | | 23 | 63 | 100 | 63 | 249 | | | | | | | 230,000 | 630,000 | 1,000,000 | 630,000 | 2,490,000 |
| | គ | គ្មាន | - | 10 | 2 | 186 | 39 | - | - | - | - | - | 237 | - | 100,000 | 20,000 | 1,860,000 | 390,000 | - | - | - | - | - | 2,370,000 |
| | | | សរុប | | | | | | | | | | 1,511 | សរុប | | | | | | | | | | 15,110,000 |
| | ក | ១ | | | | | 195 | 57 | - | - | - | - | 252 | | | | | 1,950,000 | 570,000 | - | - | - | - | 2,520,000 |
| | | ២ | | | | | | | 38 | 65 | 43 | 177 | 323 | | | | | | | 380,000 | 650,000 | 430,000 | 1,770,000 | 3,230,000 |
| | | ៣ | | | | | | | 8 | 34 | 18 | 13 | 73 | | | | | | | 80,000 | 340,000 | 180,000 | 130,000 | 730,000 |
| | | ១ | | | | | 4 | - | - | - | - | - | 4 | | | | | 40,000 | - | - | - | - | - | 40,000 |

... ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## ✦ សន្លឹកឈ្មោះ WIFE

គឺសម្រាប់បង្ហាញតួលេខនិងចំណាយលើអ្នកក្នុងបន្ទុកតាមឋានន្តរស័ក្តិនិងថ្នាក់ដែលបានគណនាស្រង់ចេញពីតារាងបៀវត្សទាំងស្រុង មានន័យថាមិនបានគណនាតួលេខបម្រែបម្រួលដែលអ្នកប្រើប្រាស់បានបញ្ចូលនៅឡើងទេ។

**តារាងសម្រាប់អ្នកក្នុងបន្ទុកពីតារាងបៀវត្ស**

| ខែ | បខ័ណ្ឌ | ានន្តរស័ | ចំនួនមន្ត្រីរាជការសកម្មតាមឋានន្តរស័ក្តិ និងថ្នាក់ | | | | | | | | | | សរុប | គម្រោងចំណាយបៀវត្សមូលដ្ឋានមន្ត្រីរាជការសកម្មតាមឋានន្តរស័ក្តិ និងថ្នាក់ | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ | | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ | |
| មករា | ក | ១ | | | | | 91 | 29 | 3 | - | - | - | 123 | | | | | 1,365,000 | 435,000 | 45,000 | - | - | - | 1,845,000 |
| | | ២ | | | | | | | 7 | 18 | 9 | 47 | 81 | | | | | | | 105,000 | 270,000 | 135,000 | 705,000 | 1,215,000 |
| | | ៣ | | | | | | | 4 | 7 | 4 | 2 | 17 | | | | | | | 60,000 | 105,000 | 60,000 | 30,000 | 255,000 |
| | ខ | ១ | | | | | 2 | - | - | - | - | - | 2 | | | | | 30,000 | - | - | - | - | - | 30,000 |
| | | ២ | | | | | | | 16 | 37 | 90 | 26 | 169 | | | | | | | 240,000 | 555,000 | 1,350,000 | 390,000 | 2,535,000 |
| | | ៣ | | | | | | | 1 | 12 | 25 | 12 | 50 | | | | | | | 15,000 | 180,000 | 375,000 | 180,000 | 750,000 |
| | គ | គ្មាន | - | 3 | 1 | 49 | 10 | - | - | - | - | - | 63 | - | 45,000 | 15,000 | 735,000 | 150,000 | - | - | - | - | - | 945,000 |
| | | | សរុប | | | | | | | | | | 505 | សរុប | | | | | | | | | | 7,575,000 |
| កុម្ភៈ | ក | ១ | | | | | 91 | 29 | 3 | - | - | - | 123 | | | | | 1,365,000 | 435,000 | 45,000 | - | - | - | 1,845,000 |
| | | ២ | | | | | | | 7 | 18 | 9 | 47 | 81 | | | | | | | 105,000 | 270,000 | 135,000 | 705,000 | 1,215,000 |
| | | ៣ | | | | | | | 4 | 7 | 4 | 2 | 17 | | | | | | | 60,000 | 105,000 | 60,000 | 30,000 | 255,000 |
| | ខ | ១ | | | | | 2 | - | - | - | - | - | 2 | | | | | 30,000 | - | - | - | - | - | 30,000 |
| | | ២ | | | | | | | 16 | 37 | 90 | 26 | 169 | | | | | | | 240,000 | 555,000 | 1,350,000 | 390,000 | 2,535,000 |
| | | ៣ | | | | | | | 1 | 12 | 25 | 12 | 50 | | | | | | | 15,000 | 180,000 | 375,000 | 180,000 | 750,000 |
| | គ | គ្មាន | - | 3 | 1 | 49 | 10 | - | - | - | - | - | 63 | - | 45,000 | 15,000 | 735,000 | 150,000 | - | - | - | - | - | 945,000 |
| | | | សរុប | | | | | | | | | | 505 | សរុប | | | | | | | | | | 7,575,000 |
| | ក | ១ | | | | | 91 | 29 | 3 | - | - | - | 123 | | | | | 1,365,000 | 435,000 | 45,000 | - | - | - | 1,845,000 |
| | | ២ | | | | | | | 7 | 18 | 9 | 47 | 81 | | | | | | | 105,000 | 270,000 | 135,000 | 705,000 | 1,215,000 |
| | | ៣ | | | | | | | 4 | 7 | 4 | 2 | 17 | | | | | | | 60,000 | 105,000 | 60,000 | 30,000 | 255,000 |
| មីនា | | ១ | | | | | 2 | - | - | - | - | - | 2 | | | | | 30,000 | - | - | - | - | - | 30,000 |

ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION

## ✦ សន្លឹកឈ្មោះ POSITION

គឺសម្រាប់បង្ហាញតួលេខប្រាក់បំណាច់មុខងារតាមឋានន្តរស័ក្តិនិងថ្នាក់ដែលបានគណនាស្រង់ចេញពីតារាងបៀវត្សទាំងស្រុង មានន័យថាមិនបានគណនាតួលេខបម្រែបម្រួលដែលអ្នកប្រើប្រាស់បានបញ្ចូលនៅឡើងទេ។

**តារាងសម្រាប់ប្រាក់បំណាច់មុខងារតាមឋានន្តរស័ក្តិនិងថ្នាក់ពីតារាងបៀវត្ស**

| ខែ | ក្របខ័ណ្ឌ | ឋានន្តរស័ក្តិ | ចំនួនមន្ត្រីរាជការសកម្មតាមឋានន្តរស័ក្តិ និងថ្នាក់ | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ | |
| មករា | ក | ១ | | | | | 130,110,000 | 44,310,000 | 2,560,000 | - | - | - | 176,980,000 |
| | | ២ | | | | | | | 23,470,000 | 34,970,000 | 18,990,000 | 96,750,000 | 174,180,000 |
| | | ៣ | | | | | | | 19,530,000 | 41,030,000 | 22,840,000 | 11,420,000 | 94,820,000 |
| | ខ | ១ | | | | | 3,830,000 | - | - | - | - | - | 3,830,000 |
| | | ២ | | | | | | | 36,580,000 | 49,090,000 | 145,130,000 | 37,850,000 | 268,650,000 |
| | | ៣ | | | | | | | 19,840,000 | 79,980,000 | 79,800,000 | 53,180,000 | 232,800,000 |
| | គ | គ្មាន | 12,050,000 | 9,150,000 | 4,270,000 | 189,290,000 | 22,590,000 | 610,000 | - | - | - | - | 237,960,000 |
| | | | សរុប | | | | | | | | | | 1,189,220,000 |
| កុម្ភៈ | ក | ១ | | | | | 130,110,000 | 44,310,000 | 2,560,000 | - | - | - | 176,980,000 |
| | | ២ | | | | | | | 23,470,000 | 34,970,000 | 18,990,000 | 96,750,000 | 174,180,000 |
| | | ៣ | | | | | | | 19,530,000 | 41,030,000 | 22,840,000 | 11,420,000 | 94,820,000 |
| | ខ | ១ | | | | | 3,210,000 | - | - | - | - | - | 3,210,000 |
| | | ២ | | | | | | | 36,580,000 | 49,090,000 | 145,130,000 | 37,850,000 | 268,650,000 |
| | | ៣ | | | | | | | 19,840,000 | 79,980,000 | 79,180,000 | 53,180,000 | 232,180,000 |
| | គ | គ្មាន | 12,050,000 | 9,150,000 | 4,270,000 | 189,290,000 | 22,590,000 | 610,000 | - | - | - | - | 237,960,000 |
| | | | សរុប | | | | | | | | | | 1,187,980,000 |
| | ក | ១ | | | | | 130,110,000 | 44,310,000 | 2,560,000 | - | - | - | 176,980,000 |
| | | ២ | | | | | | | 23,470,000 | 34,970,000 | 18,990,000 | 96,750,000 | 174,180,000 |
| | | ៣ | | | | | | | 19,530,000 | 41,030,000 | 22,840,000 | 11,420,000 | 94,820,000 |
| មីនា | ខ | ១ | | | | | 3,210,000 | - | - | - | - | - | 3,210,000 |
| | | ២ | | | | | | | 36,580,000 | 49,090,000 | 144,480,000 | 37,850,000 | 268,000,000 |

ETA | INFO | A | B | I | II | III | IV | V | VI | VII | VIII | IX | Total_A | Total_B | Plan | T3A | Status | CHILD | WIFE | POSITION